00815806

E201/2

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 14 / 06 / 2012
ម៉ោង (Time/Heure): 08:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២

**ជូនចំពោះ:** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង;មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ:** **សេចក្តីជូនដំណឹងទៅភាគីពាក់ព័ន្ធនឹងនីតិវិធីនៃការកែសម្រួលការសួរសំណួរ និងចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំការបំភ្លឺទាក់ទងនឹងការប្រើប្រាស់ឯកសារនានាក្នុងពេលផ្តល់សក្ខីកម្មរបស់សាក្សី (ឯកសារ E201)**

អង្គជំនុំជម្រះសាលាដំបូងសូមរំឭកភាគីថា ដើម្បីផលប្រយោជន៍នៃការធានាបាននូវភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធីនោះ នាពេលថ្មីៗនេះ អង្គជំនុំជម្រះបានចាប់ផ្តើមសួរសំណួរទៅសាក្សីម្នាក់ៗដែលមកផ្តល់សក្ខីកម្មថាតើសាក្សីបានពិនិត្យមើលឡើងវិញនូវចម្លើយដែលខ្លួនបានផ្តល់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស) ដែរ ឬទេ ហើយថាតើចម្លើយទាំងនេះជាចម្លើយត្រឹមត្រូវដែលសាក្សីបានឆ្លើយនៅដំណាក់កាលស៊ើបអង្កេត មែន ឬយ៉ាងណា។ ក្នុងករណីដែលសាក្សីគូសបញ្ជាក់ ថាខ្លួនពិតជាចាំចម្លើយរបស់ខ្លួន ហើយខ្លឹមសារនៃចម្លើយដូចដែលបានកត់ត្រានៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ ក.ស.ច.ស មានភាពត្រឹមត្រូវ ភាគីមិនត្រូវស្នើផ្ទួនៗសុំឱ្យសាក្សីបញ្ជាក់អំពីការពិតនេះ ឬព្យាយាមបង្ខំសាក្សីឱ្យរៀបរាប់ឡើងវិញអំពីខ្លឹមសារនៃចម្លើយនោះឡើយ។ ជំនួសមកវិញ ភាគីគួរគប្បីផ្តោតការខិតខំរបស់ខ្លួនលើសំណួរផ្សេងៗ (ឧទាហរណ៍ សំណួរស្តីពីបញ្ហានានាដែលពុំស្ថិតនៅក្នុងខ្លឹមសារនៃចម្លើយ) ឬការជំទាស់តវ៉ាជាក់លាក់ទៅនឹងភាពអាចជឿជាក់បាននៃចម្លើយ ឬភស្តុតាងរបស់សាក្សី។

អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញបន្ថែមទៀតនូវសំណើ E201 របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ៣០ខែ ឧសភា ឆ្នាំ ២០១២ ដែលក្នុងនោះសហព្រះរាជអាជ្ញាបានជូនដំណឹងជាមុនមកអង្គជំនុំជម្រះ និងភាគីអំពីចេតនារបស់ខ្លួនក្នុងការប្រើប្រាស់ឯកសារនានាដើម្បី (១) រំឭកការចងចាំរបស់សាក្សី (២) ឆ្លើយថាភាពលើឯកសារផ្តល់ជូនណាមួយ ឬដើម្បីជួយដល់អង្គជំនុំជម្រះនៅក្នុងការវាយតម្លៃអំពីទម្ងន់ដែលគួរផ្តល់ជាស្ថាពរទៅឯកសារនោះ (៣) បញ្ជាក់ការពិតអំពីខ្លឹមសារ ឬទាញការសន្និដ្ឋានពីខ្លឹមសារនៃឯកសារណាមួយ ដោយផ្អែកលើការដឹងឮផ្ទាល់របស់សាក្សី ឬ (៤) វាយតម្លៃអំពីភាពអាចជឿជាក់បានរបស់សាក្សី។ ដោយហេតុថាសំណើ E201 បានត្រឹមតែលើកយកច្បាប់មកគូសបញ្ជាក់ឡើងវិញ និងស្របជាមួយសេចក្តីណែនាំមុនៗដែលអង្គជំនុំជម្រះបានផ្តល់ និងពុំបានសំណូមពរជាក់លាក់ឱ្យហួសពីការបញ្ជាក់បំភ្លឺ ទើបពុំមានចម្លើយតបណាមួយទៅនឹងសំណើនេះនឹងត្រូវបានយកមកពិចារណាដោយ អង្គជំនុំជម្រះ។ ដើម្បីធានាប្រសិទ្ធភាពសវនាការ អង្គជំនុំជម្រះសូមស្នើភាគីពាក់ព័ន្ធថានៅពេលដែលការប្រាស្រ័យទាក់ទងការងារនៅថ្ងៃមុខ ធ្វើឡើងគ្រាន់តែដើម្បីជូនដំណឹងមកអង្គជំនុំជម្រះ និងភាគី ឬដើម្បីស្នើសុំការបញ្ជាក់បំភ្លឺ ការប្រាស្រ័យទាក់ទងការងារនេះគួរត្រូវបានធ្វើតាមរយៈមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងជំនួសវិញ។ មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង នឹងបញ្ជូនលិខិតប្រាស្រ័យទាក់ទងការងារទាំងអស់ ដែលខ្លួនបានទទួលជំនួសមុខឱ្យអង្គជំនុំជម្រះទៅឱ្យចៅក្រម និងភាគីផ្សេងៗតាមការសមស្រប។ ថ្វីដ្បិតអង្គជំនុំជម្រះយល់ឃើញថាគោលការណ៍ទាំងឡាយដែលសហព្រះរាជអាជ្ញាបានចង្អុលបង្ហាញ ត្រូវបានទទួលស្គាល់ដោយវិធាននានាដែលបង្កើតឡើងក្នុងកម្រិតអន្តរជាតិក៏ដោយ ក៏អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថាសាក្សីជាច្រើននៅចំពោះមុខ អ.វ.ត.ក មានវ័យចំណាស់។ ក្រៅពីជាមនុស្សចាស់ សាក្សីទាំងនេះមានបញ្ហាភ្នែក និងត្រចៀកជាញឹកញាប់ ឬពុំសូវចេះអក្សរ។ ប្រការនេះនាំឱ្យការដាក់ឯកសារក្នុងចំនួនច្រើន ទៅឱ្យសាក្សី ប្រភេទនេះ អាចនាំមកនូវលទ្ធផលតិចតួច និងប៉ះពាល់ដល់ប្រសិទ្ធភាពនៃសវនាការ។ តាមហេតុផលទាំងនេះ អង្គជំនុំជម្រះបានលើកទឹកចិត្តភាគីក្នុងការតាំងសំណួរដោយផ្ទាល់មាត់ពាក់ព័ន្ធនឹងខ្លឹមសារនៃឯកសារណាដែលអាចត្រូវបានអនុញ្ញាតឱ្យដាក់ទៅឱ្យសាក្សីពិនិត្យ។

ជាចុងក្រោយ អង្គជំនុំជម្រះសូមរំឭកភាគីថាដោយហេតុថាសំណុំរឿង ០០២/០១ គឺជាការជំនុំជម្រះតាមប្រព័ន្ធច្បាប់ស៊ីវិល ពុំមានភាពចាំបាច់ដើម្បីបង្ហាញឯកសារតាមរយៈតែសាក្សីឡើយ។ ភាគីធ្លាប់ត្រូវបានផ្តល់ឱកាសដើម្បីបង្ហាញឯកសារនានា ដែលខ្លួនយល់ថាពាក់ព័ន្ធបំផុតទៅនឹងផ្នែកនៃអង្គហេតុដែលត្រូវធ្វើសវនាការ នៅពេលបិទបញ្ចប់នៃការធ្វើសវនាការលើចំណុចអង្គហេតុនីមួយៗ។ អង្គជំនុំជម្រះសាលាដំបូងពិចារណាអំពីការបន្តទម្លាប់អនុវត្តនេះ ទាក់ទិននឹងចំណុចអង្គហេតុដែលត្រូវធ្វើសវនាការនាពេលបច្ចុប្បន្ន និងនៅពេលក្រោយ។